ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខាធិការដ្ឋាន

លេខៈ ០១៤ សសរ /គ.ជ.អ.ប

# សេចក្តីសម្រេច
## ស្តីពី
## ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំនៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)

## លេខាធិការដ្ឋាន គ.ជ.អ.ប.

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩/០៦ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៨៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា២ មាត្រា១៨ នៃព្រះរាជក្រឹត្យលេខនស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២៤/៥៩៣ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីតែងតាំងមុខតំណែងថ្នាក់ដឹកនាំក្នុងរចនាសម្ព័ន្ធលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៥ និងមាត្រា១៧ និងបន្ថែមមាត្រា១២ស្ទួន នៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.
- យោងតាមតម្រូវការចាំបាច់របស់លេខាធិការដ្ឋាន គ.ជ.អ.ប.

លេខាធិការដ្ឋាន

១៥

# **សម្រេច**

**ប្រការ ១._**

**ឯកឧត្តម ចាន់ សុផា** ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវដឹកនាំការងាររួមរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងទទួលលើការងារអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ និងក្រុមសវនកម្មផ្ទៃក្នុង។

**ប្រការ ២._**

ត្រូវបានបែកចែកភារកិច្ចជូនអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីជួយប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ដូចខាងក្រោម ៖

១. **ឯកឧត្តម ឡាយ ណារិទ្ធ** អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលជួយប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. លើកិច្ចការដូចខាងក្រោម៖

- គ្រប់គ្រង ចាត់ចែង និងផ្តល់សេវាគាំទ្រផ្នែករដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការអនុវត្តកម្មវិធីជាតិ និងផែនការអនុវត្តកម្មវិធីជាតិ
- គ្រប់គ្រងបុគ្គលិករបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងបុគ្គលិកកិច្ចសន្យានៃគម្រោង/កម្មវិធីដែលប្រើប្រាស់ប្រតិបត្តិការរដ្ឋបាល និងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប.
- គ្រប់គ្រងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.
- គ្រប់គ្រងឯកសារចេញ-ចូល ទ្រព្យសម្បត្តិ និងបញ្ជីសារពើភ័ណ្ឌរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.
- ចាត់ចែងកិច្ចការសវនកម្មផ្ទៃក្នុង និងសវនកម្មផ្ទៃក្រៅ
- អនុវត្តកិច្ចការផ្សេងទៀតតាមការចាត់តាំងរបស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.។

២. **ឯកឧត្តម នី គីមសាន** អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលជួយប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. លើកិច្ចការដូចខាងក្រោម៖

- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការកៀរគរធនធាន និងការគាំទ្រនានាមកលើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ដឹកនាំការសិក្សា និងស្វែងរកលទ្ធភាពក្នុងរៀបចំគម្រោង និងកម្មវិធីដាច់ដោយឡែក
- សម្របសម្រួល និងដឹកនាំរៀបចំ និងអនុវត្តគម្រោង និងកម្មវិធីដាច់ដោយឡែក
- បន្សុីគម្រោង ឬកម្មវិធីដាច់ដោយឡែកជាមួយនឹងសកម្មភាពដែលមានកំណត់ក្នុងកម្មវិធីជាតិ
- ទទួលដឹកនាំគណៈកម្មការផ្តល់មូលនិធិផ្អែកលើលទ្ធផលនៃការអនុវត្តសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ទទួលជានាយកគម្រោងអាហារូបត្ថម្ភនៅកម្ពុជា (Cambodia Nutrition Project-CNP)

- ទទួលជានាយកគម្រោងពង្រឹងភាពធន់ប្រព័ន្ធធារាសាស្ត្រ និងកសិកម្មប្រកបដោយចីរភាព (Climate Adaptive Irrigation and Sustainable Agriculture for Resilience-CAISAR)
- សម្របសម្រួល និងដឹកនាំរៀបចំឯកសារទស្សនទាន រៀបចំសិក្សាគម្រោងពាណិជ្ជកម្មកសិកម្មធន់នឹងការប្រែប្រួលអាកាសធាតុ និងពិពិធកម្មទីផ្សារ (Climate Resilient Agriculture Commercialization and Market Diversification Project) និងអនុវត្តគម្រោងដែលគ្រោងដោយហិរញ្ញប្បទានធនាគារអភិវឌ្ឍន៍អាស៊ី
- សម្របសម្រួល និងដឹកនាំរៀបចំឯកសារទស្សនទាន រៀបចំសិក្សាគម្រោងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានធន់នឹងការប្រែប្រួលអាកាសធាតុប្រកបដោយចីរភាព (Sustainable Climate Resilient Accelerated Local Economic Development Project-SCALED) និងអនុវត្តគម្រោង ដែលគ្រោងហិរញ្ញប្បទានដោយធនាគារពិភពលោក
- អនុវត្តកិច្ចការផ្សេងទៀតតាមការចាត់តាំងរបស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.។

៣. **ឯកឧត្តម ម៉ាអុន ម៉ាអូណាត** អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលជួយប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. លើកិច្ចការដូចខាងក្រោម៖

- រៀបចំ និងអនុវត្តក្របខ័ណ្ឌការងារត្រួតពិនិត្យ និងវាយតម្លៃលើការរៀបចំ និងអនុវត្តក្របខ័ណ្ឌគតិយុត្តសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីជាតិ និងផែនការអនុវត្តកម្មវិធីជាតិ
- រៀបចំ និងអនុវត្តក្របខ័ណ្ឌការងារសម្រាប់ការសិក្សា ស្រាវជ្រាវ និងអង្កេតស្ដីពីផលប៉ះពាល់នានានៃការអនុវត្តកម្មវិធីជាតិ និងផែនការអនុវត្ត
- រៀបចំ ចងក្រង និងផ្សព្វផ្សាយទិន្នន័យ ព័ត៌មាន និងឯកសារនានាពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- គាំទ្រ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យារបស់លេខាធិការដ្ឋាន គ.ជ.អ.ប.
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការគាំទ្រដល់លេខាធិការដ្ឋាន គ.ជ.អ.ប.
- សម្របសម្រួល និងដឹកនាំការអនុវត្តការងារគណនេយ្យភាពសង្គម
- អនុវត្តកិច្ចការផ្សេងទៀតតាមការចាត់តាំងរបស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.។

៤. **ឯកឧត្តម ឈុន ម៉ុនណារ៉ា** អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលជួយប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. លើកិច្ចការដូចខាងក្រោម៖

- រៀបចំ គាំទ្រ និងអនុវត្តកម្មវិធីជាតិ និងផែនការអនុវត្តកម្មវិធីជាតិ
- សម្របសម្រួលត្រួតពិនិត្យ និងតាមដានការអនុវត្តកម្មវិធីជាតិ និងផែនការអនុវត្តកម្មវិធីជាតិ

- ដឹកនាំរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. និងផែនការយុទ្ធសាស្ត្រថវិការបស់លេខាធិការដ្ឋាន គ.ជ.អ.ប.
- ដឹកនាំរៀបចំរបាយការណ៍វឌ្ឍនភាពកម្មវិធីជាតិ និងរបាយការណ៍សមិទ្ធកម្ម
- ចាត់ចែងកិច្ចលទ្ធកម្ម សម្ភារ និងការងារសាងសង់នានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប.
- ដឹកនាំការត្រួតពិនិត្យសុវត្ថិភាពបរិស្ថាន និងសង្គម និងផែនការបន្ធូរបន្ថយផលប៉ះពាល់លើសុវត្ថិភាពបរិស្ថាន និងសង្គម
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការគាំទ្រការអនុវត្តកម្មវិធីជាតិ និងកិច្ចការចាំបាច់ផ្សេងទៀត
- ទទួលបន្ទុកជាប្រធានគម្រោង (Climate Adaptive Irrigation and Sustainable Agriculture for Resilience-CAISAR)
- អនុវត្តកិច្ចការផ្សេងទៀតតាមការចាត់តាំងរបស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.។

៥. **ឯកឧត្តម ឆេង ទឡ្ហៈ** អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលជួយប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. លើការងារប្រែប្រួលអាកាសធាតុ មូលនិធិអាកាសធាតុបៃតង និងមូលនិធិអាកាសធាតុផ្សេងៗទៀត លើកិច្ចការដូចខាងក្រោម៖

- រៀបចំគោលនយោបាយ កម្មវិធី ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពពាក់ព័ន្ធនឹងការងារប្រែប្រួលអាកាសធាតុរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.
- សម្របសម្រួលជាមួយស្ថាប័នជាតិ និងអន្តរជាតិក្នុងការរៀបចំ និងអនុវត្តគម្រោង និងកម្មវិធីសម្រាប់មូលនិធិអាកាសធាតុបៃតង និងមូលនិធិអាកាសធាតុផ្សេងៗ
- ដឹកនាំ និងសម្របសម្រួលក្នុងការរៀបចំ និងអនុវត្តកិច្ចព្រមព្រៀង ព្រមទាំងតាមដានត្រួតពិនិត្យវាយតម្លៃ និងគ្រប់គ្រងព័ត៌មាននានារវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងមូលនិធិអាកាសធាតុបៃតង ឬមូលនិធិអាកាសធាតុផ្សេងៗ និងរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយក្រសួង ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានហិរញ្ញវត្ថុ និងអង្គការមិនមែនរដ្ឋាភិបាលនានា
- ដឹកនាំរៀបចំរបាយការណ៍នានាដែលពាក់ព័ន្ធនឹងការងារប្រែប្រួលអាកាសធាតុ មូលនិធិអាកាសធាតុបៃតង មូលនិធិអាកាសធាតុផ្សេងៗ និងអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- ដឹកនាំរៀបចំការទទួលស្គាល់សមត្ថភាពស្ថាប័នសម្រាប់មូលនិធិអាកាសធាតុបៃតង និងស្ថាប័នអាកាសធាតុផ្សេងៗទៀត
- ដឹកនាំការអង្កេត និងដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងគម្រោង និងកម្មវិធីដាច់ដោយឡែក
- ដឹកនាំរៀបចំ និងអនុវត្តគម្រោងពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីសង្គមធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
- អនុវត្តកិច្ចការផ្សេងទៀតតាមការចាត់តាំងរបស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.។

លេខាធិការដ្ឋាន

**ប្រការ ៣._**

សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤._**

អនុប្រធានលេខាធិការដ្ឋានគ.ជ.អ.ប. ប្រធានអង្គភាពវិភាគនិងអភិវឌ្ឍន៍គោលនយោបាយ ប្រធានអង្គភាពត្រួតពិនិត្យ វាយតម្លៃនិងព័ត៌មាន ប្រធានអង្គភាពរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធានអង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី ប្រធានក្រុមសវនកម្មផ្ទៃក្នុង និងសាមីខ្លួនដែលមានចែងក្នុងប្រការ២ នៃសេចក្តីសម្រេចនេះ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃ សុក្រ ១៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០២៤

**រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ**

**និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.**

**ចាន់ សុធា**

**<u>កន្លែងទទួល</u> ៖**

- ខុទ្ទកាល័យ**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ**... 

- ខុទ្ទកាល័យ**ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.**
- ខុទ្ទកាល័យ**ឯកឧត្តមទេសរដ្ឋមន្ត្រី** ទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប.
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ